ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Oct-2015, 13:23
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

---

# ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F30

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“**អង្គជំនុំជម្រះតុលាការកំពូល**” និង“**អ.វ.ត.ក**”),

**កត់សម្គាល់**ឃើញថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”) ដែលបានចេញនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[1],

**បានទទួល** បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន[2],

**រំលឹកថា** នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានផ្ញើអ៊ីមែលជាការគួរសមទៅកាន់ភាគី ជូនដំណឹងថា អង្គជំនុំជម្រះមានគម្រោងបើកសវនាការបណ្តឹងសាទុក្ខនៅចន្លោះថ្ងៃទី ១០ និង ២០ វិច្ឆិកា ឆ្នាំ ២០១៥[3],

**រំលឹកថា** យោងតាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង[4] ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ ថា អង្គជំនុំជម្រះ នឹងបើកសវនាការលើបណ្តឹងសាទុក្ខចាប់ពីថ្ងៃ ច័ន្ទ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដល់ថ្ងៃ ពុធ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ រួមទាំង

---

[1] សាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ E313។

[2] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារលេខ F11។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F16។ *[កែតម្រូវលើកទី ១] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១* ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F17 (សំណៅត្រូវបានកែតម្រូវ ដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។ សូមមើល សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបណ្តឹងសាទុក្ខលើសេចក្តីសម្រេចក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/3/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/1/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារលេខ E313/2/1។

[3] អ៊ីមែលជាអេឡិចត្រូនិចពីមន្ត្រីច្បាប់ និងក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា “Re: ការបញ្ជាក់ពីដីកាកំណត់កាលបរិច្ឆេទបណ្តោះអាសន្ន” នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥ ម៉ោង ១២ និង ៤៣ នាទីល្ងាចនៅមុខអង្គជំនុំជម្រះតុលាការកំពូល។

[4] វិធានផ្ទៃក្នុងរបស់ អវតក វិសោធនកម្មលើកទី ៩ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ (“វិធានផ្ទៃក្នុង”)។

សវនាការលើភស្តុតាងដែលអាចនឹងធ្វើឡើងមុន និងថា ដីកាកំណត់កាលបរិច្ឆេទសវនាការដែលបញ្ជាក់ពីចំណុចលម្អិត នឹងត្រូវចេញក្នុងពេលឆាប់ៗខាងមុខនេះ[5],

**កត់សម្គាល់**ឃើញថា សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋមួយចំនួននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅដំណាក់កាលទីមួយ និងទីពីរនៃការជម្លៀសប្រជាជន និងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ នៅក្នុងការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការជួយជំរុញ ព្រមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើ ប៉ុន្តែ មានការជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋមួយចំនួនតែប៉ុណ្ណោះ ដែលបានផ្អែកលើទម្រង់នៃការទទួលខុសត្រូវនៅក្នុង"សហឧក្រិដ្ឋកម្មរួម",

**កត់សម្គាល់**ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើបទឧក្រិដ្ឋនៃការសម្លាប់រង្គាល (ដោយរួមបញ្ចូលការធ្វើមនុស្សឃាតនៅដំណាក់កាលទីមួយនៃការជម្លៀសប្រជាជន) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការជម្លៀសដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន) នៅដំណាក់កាលទីពីរនៃការជម្លៀសប្រជាជន និងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើបទឧក្រិដ្ឋនៃការសម្លាប់រង្គាល (រួមបញ្ចូលការធ្វើមនុស្សឃាត) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃលើទម្រង់នៃការទទួលខុសត្រូវនៅក្នុងការរៀបចំផែនការ ការបញ្ជា (ពាក់ព័ន្ធតែ នួន ជា ម្នាក់គត់) ការញុះញង់ និងការជួយជំរុញ ព្រមទាំងការទទួលខុសត្រូវរបស់ថ្នាក់លើ (ពាក់ព័ន្ធតែ នួន ជា ម្នាក់គត់)[6],

**កត់សម្គាល់**ឃើញថា ក្នុងការអនុវត្តតាមបទចោទ ដែលបានកំណត់នៅក្នុង**ដីកាដំណោះស្រាយ**[7] អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដាក់ពិរុទ្ធភាព ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ ដែលមាននៅក្នុងសហឧក្រិដ្ឋកម្មរួម តែឯងប៉ុណ្ណោះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃបទការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត (ដូចជាការជម្លៀសដោយ

---

[5] សេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ តាមវិធាន ១០៨(៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F29។

[6] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤០ ដល់ ៩៤២ (ពាក់ព័ន្ធនឹង នួន ជា) និង ១០៥៣ ដល់ ១០៥៤ (ពាក់ព័ន្ធនឹង ខៀវ សំផន)។

[7] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៨០ និង ៨១២។

បង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅដំណាក់កាលទីមួយ និងទីពីរនៃការជម្លៀសប្រជាជន និងបទការសម្លាប់រង្គាល(រួមបញ្ចូលការធ្វើមនុស្សឃាត) ទាក់ទងនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ និងថា អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងបទឧក្រិដ្ឋទាំងនោះ បានសម្រេចពុំដាក់ពិរុទ្ធភាព ដោយផ្អែកលើការទទួលខុសត្រូវនៅក្នុងការរៀបចំផែនការ ការបញ្ជា ការញុះញង់ ឬការជួយជំរុញ ដោយបានយល់ឃើញថា "ការចូលរួមរបស់ ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួម គឺបានរួមបញ្ចូលអំពើទាំងអស់ដែលបង្កើតបានជាការសម្អាងនៃការយល់ឃើញរបស់អង្គជំនុំជម្រះ ទៅលើទម្រង់នៃការទទួលខុសត្រូវដទៃទៀតនេះ" និងថា អង្គជំនុំជម្រះ ពុំបានសម្រេចដាក់ពិរុទ្ធភាព ដោយផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើពាក់ព័ន្ធនឹង នួន ជា "ដោយបានយល់ឃើញថា ជនជាប់ចោទ ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើបទឧក្រិដ្ឋទាំងនោះ តាមរយៈការចូលរួមរបស់ខ្លួននៅក្នុងសហឧក្រិដ្ឋកម្មរួម"[8],

**ពិចារណាឃើញ**ថា ដីកាដំណោះស្រាយ និងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ពុំមានការពន្យល់ពីមូលហេតុអ្វីបានជា ទម្រង់នៃការទទួលខុសត្រូវ ត្រូវបានចោទប្រកាន់យ៉ាងដូច្នេះឡើយ និងពុំបានបង្ហាញនូវមូលហេតុច្បាស់លាស់ណាមួយផងដែរ បើផ្អែកតាមការចោទប្រកាន់អង្គហេតុប្រឆាំងនឹង នួន ជា និង ខៀវ សំផន នៅក្នុងដីកាដំណោះស្រាយ និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ,

**រំលឹក**ថា វិធាន ១១០(២) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល"កែប្រែបទចោទប្រកាន់ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់" ចែងថា ការកែប្រែ ពុំមែន"ជាការបន្ថែមធាតុផ្សំថ្មីនៃបទល្មើសណាមួយ ដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូង" ឡើយ[9]។

**ពិចារណាឃើញ**ថា ជាការសមស្របក្នុងការជូនដំណឹងភាគីជាមុន អំពីលទ្ធភាពនៃការកែប្រែ"បទចោទប្រកាន់នេះ"[10] និងផ្តល់ឱកាសដល់ភាគីក្នុងការដាក់សារណាលើបញ្ហានេះផងដែរ[11]។

---

[8] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៩៤០ ដល់ ៩៤១ (ពាក់ព័ន្ធនឹង នួន ជា ) និង ១០៥៣ (ពាក់ព័ន្ធនឹង ខៀវ សំផន)។

[9] *សូមមើល* មាត្រា ៤០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[10] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

[11] *សូមមើលរឿងក្តី Pélissier និង Sassi ទល់នឹង ប្រទេសបារាំង* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស"សាលក្រមរបស់អង្គជំនុំជម្រះជាន់ខ្ពស់" សំណើសុំលេខ 2544/94 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១។ *រឿងក្តី Dallos ទល់នឹង Hungary*, តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស "សាលក្រមរបស់អង្គជំនុំជម្រះ" សំណើសុំលេខ 29082/95 ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០១ កថាខណ្ឌ ៤៧។ *រឿងក្តី Drassich ទល់នឹងប្រទេសអ៊ីតាលី* តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស"Arrêt" សំណើសុំលេខ 25575/04, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៣៤ ដល់ ៣៦។

## អាស្រ័យហេតុនេះសម្រេច÷

**បង្គាប់**ថា សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក ដោយអនុលោមតាមវិធាន ១០៩ នៃវិធានផ្ទៃក្នុង នឹងត្រូវធ្វើឡើងនៅថ្ងៃ ច័ន្ទ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ម៉ោង ៩:00 ព្រឹក នៅក្នុងបន្ទប់សវនាការធំនៃ អ.វ.ត.ក និងបន្តនៅថ្ងៃ អង្គារ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងថ្ងៃ ពុធ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ហើយនៅថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ គឺជាថ្ងៃបម្រុង។

**ភ្ជាប់ជាមួយ** កាលវិភាគបណ្តោះអាសន្នសម្រាប់សវនាការ[12],

**ស្នើឱ្យ**ភាគីដាក់សេចក្តីសង្កេតរបស់ខ្លួនលើកាលវិភាគនេះ ប្រសិនបើមាន ត្រឹមថ្ងៃ ពុធ ទី ២១ ខែ តុលា ឆ្នាំ ២០១៥,

**ជូនដំណឹង**ភាគីថា អង្គជំនុំជម្រះនឹងបញ្ជាក់ នៅក្នុងសេចក្តីសម្រេចដែលនឹងត្រូវចេញក្នុងពេលសមស្រប ខាងមុខ លើបញ្ហាជាក់លាក់ ដែលភាគីត្រូវផ្តោតនៅក្នុងសារណាផ្ទាល់មាត់របស់ខ្លួន,

**ស្នើឱ្យ**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជូនដំណឹងដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលតាមរយៈអ៊ីមែលយ៉ាងយូរត្រឹមថ្ងៃ អង្គារ ទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លើបញ្ហាថាតើ ប្រសិនបើធ្វើដូច្នោះ ដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះ នឹងត្រូវអង្គុយនៅក្នុងបន្ទប់សវនាការធំក្នុងអំឡុងពេលសវនាការ,

**ជូនដំណឹង**ភាគីថា ប្រសិនបើ ការសម្រេចដាក់ពិរុទ្ធភាព ត្រូវបានធ្វើឡើងនោះ អង្គជំនុំជម្រះអាចពិចារណា "កែប្រែបទចោទប្រកាន់"[13]ពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ទៅជាទម្រង់នៃការទទួលខុសត្រូវ ដែលអង្គជំនុំជម្រះ យល់ឃើញថាសមស្រប អាចរួមទាំងការទទួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម លើបទឧក្រិដ្ឋទាំងអស់ ដែលជនជាប់ អាចនឹងត្រូវបានសម្រេចដាក់ពិរុទ្ធភាពនោះ,

**បញ្ជាក់ថា** ការជូនដំណឹងនេះ ពុំបានធ្វើឱ្យប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហាថាតើ ជាក់ស្តែង ត្រូវចាត់នីតិវិធីជាមួយនឹង"ការកែប្រែបទចោទប្រកាន់"[14] ឬក៏ការសម្រេចរបស់ខ្លួន

---

[12] ឧបសម្ព័ន្ធ ក – កាលវិភាគសម្រាប់សវនាការ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ F30.1។

[13] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

[14] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

ទាក់ទងទៅនឹងអង្គសេចក្ដីនៃទឡ្ហីករណ៍ដែលជាប់ពាក់ព័ន្ធនៅក្នុងបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន នោះឡើយ,

**ស្នើឱ្យ**ភាគីត្រូវដាក់សារណាជាលាយលក្ខណ៍អក្សរ ដែលខ្លួនអាចនឹងធ្វើឡើងទាក់ទងនឹង"ការកែប្រែបទចោទប្រកាន់"[15]ដែលជាសក្ដានុពល យ៉ាងយូរត្រឹមថ្ងៃ សុក្រ ទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ជាភាសាខ្មែរ និងអង់គ្លេស ឬបារាំង ជាកំហិតដោយគ្មានករណីលើកលែងឡើយ,

**ជូនដំណឹង**ភាគីថា ប្រសិនបើខ្លួនមានបំណងចង់ឆ្លើយតបទៅនឹងអំណះអំណាងណាមួយរបស់ភាគីដទៃទៀត ពាក់ព័ន្ធនឹង"ការកែប្រែបទចោទប្រកាន់"[16]ដែលមានសក្ដានុពលនេះ ភាគីអាចធ្វើដូច្នោះបាន ដោយផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការ តាមពេលវេលាបានកំណត់ នៅក្នុងផ្នែកសម្រាប់"ឧក្រិដ្ឋកម្មដែល នួន ជា និង ខៀវ សំផន ត្រូវបានដាក់ពិរុទ្ធ" ឬ"ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល" តាមករណីសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[15] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។

[16] វិធាន ១១០(២) នៃវិធានផ្ទៃក្នុង។